ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ
លេខ……………………………………….

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា ឆ្នាំ២០២២

**ក-អំពីកម្លាំង៖**

សរុបរួមចំនួន៖ ០៥នាក់ (ស្រី០២នាក់) អវត្តមាន៖ ០០

**ខ-សកម្មភាព និងលទ្ធផលការងារ**

ខ.១-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

<u>សកម្មភាពក្នុងស្រុក</u>

- **ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អិុន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ បាន អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី "ការត្រៀមការងារពិធីការសម្រាប់ការរៀបចំទិវាជាតិ អន្តរសាសនា លើកទី៦ ដែលដឹកនាំកិច្ចប្រជុំដោយ លោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ នៅក្នុងកិច្ចប្រជុំក្រុមការងារនៃគណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ ក្រុមការងារពិធីការក្រសួងមហាផ្ទៃ និងក្រុមការងាររៀបចំកម្មវិធី នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានព្រមព្រៀងគ្នាក្នុងការទទួលយកការងារតាមជំនាញទៅអនុវត្ត។

- **ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី ការងារត្រៀមរៀបចំទិវាជាតិអន្តរសាសនាលើកទី៦ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការ ក្រសួងមហាផ្ទៃ។ ជាលទ្ធផល អង្គប្រជុំបានធ្វើការ ឯកភាពលើរបៀបវារមួយចំនួនដូចជា ការសម្រេចលើវិធីសាស្ត្រក្នុងការរៀបចំ ទីតាំងអង្គុយសម្រាប់អ្នកចូលរួមខ្លឹមសារ នៃចំណាងជើងសម្រាប់ទិវា និងរបៀបវារៈនៃកម្មវិធីអន្តរសាសនា។

- **ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង បាន អញ្ជើញចូលរួមក្នុងកិច្ចប្រជុំពីស្តី "ការរៀបចំរបាយការណ៍ប្រចាំខែ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោម

អធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ សមាសភាព អញ្ជើញចូលរួមមាន លោកជំទាវ វេជ្ជ.ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន ប្រធានក្រុមជំនួយកិច្ចការទាំង៦ និងក្រុមការងារបូកសរុបរបាយការណ៍ របស់លេខាធិការដ្ឋាន គ.ជ.ប.ជ។

- **ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២** លោកស្រី វរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមក្នុងសិក្ខាសាលាស្តីពីលទ្ធផលស្រាវជ្រាវ «ពលករ ទេសន្តរប្រវេសន៍តាមរដូវកាល» របស់ក្រុមអ្នកស្រាវជ្រាវ ក្រោមគម្រោង ASIA CTIP តាមរយៈជំនួយឧបត្ថម្ភ ពីមូលនីធិ USAID ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំសណ្ឋាគារសាន់វេ។ សិក្ខាសាលាមានគោលបំណង ពិនិត្យមើលការអនុវត្ត ជាក់ស្តែងអំពីការធ្វើចំណាកស្រុកតាមរដូវកាល របស់ពលករកម្ពុជាទៅកាន់ប្រទេសថៃ ដែលផ្តោតទៅលើ មធ្យោបាយ របៀបរៀបរយ ភាពប្រឈមនឹងការរងគ្រោះដោយអំពើជួញដូរ ការកេងប្រវ័ញ្ច និងហានិភ័យនានា ដែលបានរកឃើញពីការសិក្សាស្រាវជ្រាវ។ សមាសភាពចូលរួមអញ្ជើញមកពី ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ថ្នាក់ដឹកនាំ គ.ខ.ប.ជ សៀមរាប មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប អង្គការដៃគូដែលជាអ្នកផ្តល់សេវាពាក់ព័ន្ធ សរុបប្រមាណ ៤០រូប ។

- **ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២** លោកវរសេនីយ៍ត្រី ធន ដារ៉ារិទ្ធ នាយរងការិយាល័យ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាសម្របសម្រួលនិកាយសាសនាសម្រាប់ចូលរួម ក្នុងទិវាជាតិអន្តរសាសនាលើកទី៦ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃខាងមុខនេះក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ មានការអញ្ជើញចូលរួមពីតំណាង ក្រសួងធម្មការសាសនា មេដឹកនាំសាសនាធំៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានព្រះពុទ្ធសាសនា ឥស្លាមសាសនា កាតូលិក ប្រូតេស្តង់ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអគ្គលេខាធិការរង ទទួលបន្ទុកលេខាធិការដ្ឋាន ប្រធានលេខាធិការដ្ឋាន នាយការិយាល័យ និងមន្ត្រីពាក់ព័ន្ធលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ តំណាងពីអង្គការការីតាសកម្ពុជា។

- **ថ្ងៃទី១០-១១ ខែកញ្ញា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមធ្វើជាគ្រូឧទ្ទេសក៍ ក្នុងវគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងការស្វែងយល់ អំពើរត់ពន្ធជួញដូរមនុស្ស និងការរំលោភបំពាននានា និងតួនាទីអ្នកស្ម័គ្រចិត្តក្នុងការចូលរួមប្រឆាំងការជួញដូរមនុស្សនៅក្នុងសហគមន៍"។ ខ្លឹមសារនៃការបណ្តុះបណ្តាលបានផ្តោតសំខាន់ទៅការពង្រឹងនៃ ការស្វែងយល់ពីបញ្ហារត់ពន្ធជួញដូរមនុស្ស ក្នុងសហគមន៍ ស្វែងយល់ពីទេសន្តរប្រវេសន៍សុវត្ថិភាព ស្វែងយល់ពីការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ

និងបញ្ជូនរកសេវា និងពង្រឹងការស្វែងយល់ពីតួនាទីអ្នកស្ម័គ្រចិត្ត ក្នុងការចូលរួមចំណែកប្រឆាំងការជួញដូរមនុស្សនៅក្នុងសហគមន៍។ អញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តនេះមានសមាសភាពចូលរួមសរុបចំនួន ២៩រូប អញ្ជើញមកពីភូមិទាំង២៩(មួយភូមិម្នាក់) នៃស្រុកកំរៀង។

- **ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី "ការបង្កើតនីតិវិធីបទដ្ឋាន នៃយន្តការបញ្ជូន ថ្នាក់ជាតិសម្រាប់ជនរងគ្រោះដោយអំពើជួញដូមនុស្ស និងជនទេសសន្តប្រវេសន៍ដែល ងាយរងគ្រោះ បានបន្តជាមួយនឹងតំណាងពីក្រសួងអភិវឌ្ឍ និងការងាររបស់គណៈកម្មាធិការជាតិ នៃរដ្ឋាភិបាលប្រទេសថៃ ដែលនឹងធ្វើការចែករំលែកនូវបទពិសោធន៍ពីនីតិវិធីបញ្ជូនថ្នាក់ជាតិ។

- **ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២** លោកស្រី វរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ បានចូលរួមសិក្ខាសាលាស្តីពី "ការបង្កើតនីតិវិធីបទដ្ឋាន នៃយន្តការបញ្ជូនថ្នាក់ជាតិសម្រាប់ ជនរងគ្រោះដោយអំពើជួញដូមនុស្ស និងជនទេសសន្តប្រវេសន៍ដែលងាយរងគ្រោះ" ដែលបាន សហការឧបត្ថម្ភគាំទ្រជាមួយអង្គការ IOM ( UN MIGRATION) ។ នៅក្នុងកិច្ចប្រជុំពិភាក្សា នោះមាន ការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ មកពីក្រសួងផែនការ, ក្រសួងកិច្ចការនារី, ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសង្គមកិច្ច, និងមានការចូលរួមពីលោក លោកស្រីមកពីស្ថាប័នពាក់ព័ន្ធ, អង្គការជាតិ អន្តរជាតិចំនួន៤៥ រូប ស្រី១៣រូប។

- **ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី "ការយកចិត្តទុកដាក់លើជនរងគ្រោះ (VSC) និងសំនុំទិន្នន័យ (Dataset) ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស" នៅសណ្ឋាគារកាំបូឌីយ៉ាណា សហការរៀបចំដោយអង្គការ អាស៊ានអាក់ ASIAN ACT ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ អញ្ជើញមានវត្តមានក្នុងពិធីបើកនៃអង្គសិក្ខាសាលា មានលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម Will Nankervis ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅកម្ពុជា និងលោកស្រី Lucia Pietropaoli ប្រធាន ASIAN ACT ថ្នាក់តំបន់ ឯកឧត្តម រដ្ឋលេខាធិការក្រសួងយុត្តិធម៌ លោកជំទាវ អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ឯកឧត្តម លោកជំទាវអគ្គលេខាធិការរង ប្រធានក្រុមជំនួយកិច្ចការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងពីស្ថាប័នយុត្តិធម៌ ថៅក្រម ព្រះរាជអាជ្ញា ខេត្តព្រះសីហនុ សៀមរាប ភ្នំពេញ ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស អគ្គស្នងការនគរបាលជាតិតំណាងពីក្រសួងសង្គមកិច្ចនិងអង្គការដៃគូរអភិវឌ្ឍ មានការពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌។

- **ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង និង លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូល

រួមក្នុងសិក្ខាសាលាស្តីពី “សំណុំទិន្នន័យស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ គោលបំណងនៃសិក្ខាសាលាគឺដើម្បីពិភាក្សា អំពីសកម្មភាពយុទ្ធសាស្ត្រ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីស្វែងរកវិធីសាស្ត្រកែលម្អ ការប្រមូលទិន្នន័យ និងការរាយការណ៍ តាមរយៈរបាយការណ៍ ប្រចាំឆ្នាំស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស។ សមាសភាពចូលរួមក្នុងសិក្ខាសាលារួមមាន ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លោកប្រធានលេខាធិការដ្ឋាន លោកប្រធាន អនុប្រធាន ក្រុមការងារ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងមន្ត្រីនៃអង្គការ អេស៊ានអាក់ សរុបចំនួន ២០រូប។

- **ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២** លោកវរសេនីយ៍ត្រី ធន ដារ៉ារិទ្ធ នាយរងការិយាល័យស្រាវជ្រាវ បានអញ្ជើញចូលរួមកិច្ចប្រជុំការងាររៀបចំអន្តរសាសនា ជាមួយគណៈកម្មការរៀបចំវេទិការ ដែលបានសហការជាមួយ គណៈកម្មាធិការរៀបចំបុណ្យជាតិ និងអន្តរជាតិ ដែលដឹកនាំកិច្ចប្រជុំដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលសន្និបាតជ្រោយចង្វា។ នៅក្នុងកិច្ចប្រជុំគណៈកម្មការរៀបចំវេទិការ អន្តរសាសនា លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក៏បាន ធ្វើការជជែកពិភាក្សាលើរបៀបវារៈមួយចំនួន ជាមួយភាគីដែលអញ្ជើញមកពីគ្រប់ស្ថាប័នពាក់ព័ន្ធ។

- **ថ្ងៃទី២៧-២៨ ខែកញ្ញា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ លោកឧត្តមសេនីយ៍ត្រី អិុន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ លោកវរសេនីយ៍ត្រី ធន ដារ៉ារិទ្ធ នាយរងការិយាល័យ ស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចង្ងាយស្តីពី “ការប្រឹក្សាសិទ្ធិមនុស្សរបស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ទទួលបន្ទុកសិទ្ធិមនុស្ស (AICHR) និងការប្រឆាំងការជួញដូរមនុស្ស ក្នុងតំបន់អាស៊ាន” ដែលបានរៀបចំ ឡើងរយៈពេល២ថ្ងៃ នៅទីក្រុងហ្សាកាតា ប្រទេសហ្វីលីពីន។ ក្នុងកិច្ចប្រជុំ នេះ លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ បានធ្វើបទបង្ហាញសង្ខេប ស្តីពីបទពិសោធន៍ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា និងបានធ្វើការឆ្លើយសំនួរពិភាក្សា ដេញដោលលើបញ្ហាមួយចំនួន។ សមាសភាពអញ្ជើញចូលរួម របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រួមមាន ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ទីប្រឹក្សាបច្ចេកទេស ប្រធាន អនុប្រធាន ក្រុមជំនួយកិច្ចការ និងមន្ត្រីពាក់ព័ន្ធ នៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

- **ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២** ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិបានចូលរួមក្នុងវេទិកាជាតិ អន្តរសាសនាលើកទី៦ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការចូលរួមរបស់សាសនាក្នុងការប្រឆាំង អំពើជួញដូរមនុស្សនៅកម្ពុជា ក្រោមអធិបតីភាព **សម្តេចអគ្គមហាសេនាបតីតេជោរ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានកិច្ចសហការជាមួយអង្គការការីតាសកម្ពុជា។ កម្មវិធីមានការអញ្ជើញចូលរួមជាគណៈអធិបតី សម្តេចព្រះមហាសង្ឃរាជាទាំងពីរគណៈ សម្តេចព្រះមហា សុមេធាធិបតី សម្តេចព្រះសង្ឃនាយក

ព្រះសង្ឃនាយករង នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូតមេដឹកនាំនៃសាសនាទាំងបី ប្រចាំ ព្រះរាជាណាចក្រកម្ពុជាសាសនា មាននិកាយឥស្លាម និកាយកាតូលិក និងប្រូតេស្តង់ ប្រធានទីភ្នាក់ការងារ អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ឯកឧត្តម លោកជំទាវ ជាអនុប្រធាន អនុប្រធានអចិន្ត្រៃយ៍ នៃ គ.ជ.ប.ជ និងថ្នាក់ដឹកនាំមន្ត្រីក្រោមឱវាទនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គណៈអភិបាលរាជធានីខេត្ត គ.ខ.ប.ជ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ និងមន្ត្រីបណ្ដាក្រសួងស្ថាប័ន ថ្នាក់ដឹកនាំសាសនាមានព្រះពុទ្ធសាសនា ទាំង២គណៈ ព្រះសង្ឃ ឥស្លាមកម្ពុជា ប្រូតេស្តង់ សាសនាគ្រីស្ទ និងអង្គពិធីជាច្រើនអង្គនាក់ទៀត តំណាង និកាយសាសនា ប្រមាណ១៥០០ អង្គនាក់។

- **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមប្រជុំដកពិសោធន៍ការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រី របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោយបញ្ចប់កម្មវិធីអន្តរសាសនាលើកទី៦ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ សមាសភាពអញ្ជើញចូលរួមមាន លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធាន/អនុប្រធាន ក្រុមជំនួយកិច្ចការទាំង៦ ប្រធានលេខាធិការដ្ឋាន អនុប្រធាន និងមន្ត្រីក្រោមឱវាទ សរុបចំនួន៣៤នាក់ (ស្រី៦នាក់)។

**ខ.២-ការងារចងក្រងព័ត៌មានតាមគេហទំព័រសារព័ត៌មាននានា** (មានភ្ជាប់ក្នុងខ្ទបសម្ព័ន្ធ)

- គ្រោះថ្នាក់ ឬហានិភ័យការងារក្នុងប្រទេសគោលដៅ
  - ឧបទ្ទវហេតុ **០០ នាក់**
  - ពលករសរុប **០០ នាក់**
- ប្រព្រឹត្តបទល្មើសនៅនឹងកន្លែង
  - ចាប់ខ្លួន **០០ នាក់**
  - ពលករសរុប **០០ នាក់**
- ពលកររួចទោសពីពន្ធនាគារ
  - ពលករសរុប **០០ នាក់**
- ពលករចំណាកស្រុកខុសច្បាប់
  - បញ្ជូនត្រឡប់ **១៣៨ នាក់**
  - ចាប់ខ្លួន **០០ នាក់**
  - ពលករសរុប **១៣៨ នាក់**

**គ-ទិសដៅបន្ត**

- បណ្ដុះបណ្ដាលជំនាញមូលដ្ឋានបច្ចេកទេសសរសេរប្រូក្រាមដល់ក្រុមការងារព័ត៌មានវិទ្យាថ្មី
- បណ្ដុះបណ្ដាលគ្រូបង្គោលនៅមណ្ឌលទទួលពលករកំរៀង

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២២

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ**

**ចម្លងជូន៖**

-លេខាធិការដ្ឋានរដ្ឋបាលសរុប

-លោកជំទាវអគ្គលេខាធិការរងទទួលបន្ទុក

-លោកជំទាវអគ្គលេខាធិការ

"ដើម្បីជូនជ្រាប" ជាសេចក្តីរាយការណ៍

-ឯកសារ-កាលប្បវត្តិ